ព្រះរាជាណាចក្រកម្ពុជា

តុលាការកំពូល

ជាតិ សាសនា ព្រះមហាក្សត្រ

សំណុំរឿងរដ្ឋប្បវេណី

លេខ: ៨១

ចុះថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០០៤

ក្នុងនាមប្រជារាស្ត្រខ្មែរ

សាលដីកា

តុលាការកំពូល

លេខ: ០២

ចុះថ្ងៃទី០៣ ខែមករា ឆ្នាំ២០០៦

បានបើកសវនាការជំនុំជំរះជាសាធារណៈនៅថ្ងៃទី០៣ ខែមករា ឆ្នាំ២០០៦ ដោយមានសមាសភាពដូចតទៅ :

១-ឯកឧត្តម ឌិត មុន្ទី ជាប្រធាន

២-លោក វៀល មួន ជាចៅក្រម

៣-លោក ស៊ិន ឌឹម ជាចៅក្រម

៤-លោក ប៉ែន សារឿន ជាចៅក្រមរបាយការណ៍

៥-លោក គង់ ភីរុន ជាចៅក្រម

ក្រឡាបញ្ជី

លោក ទៅ សុខវណ្ណ

តំណាងមហាអយ្យការ

លោកបណ្ឌិត ស៊ិន វិន្ន ជាព្រះរាជអាជ្ញា

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខ ពីសាលដីការដ្ឋប្បវេណីលេខ ៥៩"ច" ចុះថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ២០០៣ នៃសំណុំរឿងរដ្ឋប្បវេណីលេខ ៨៥៥ ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ ២០០២ របស់ សាលាឧទ្ធរណ៍រវាង :

ដើមចោទឈ្មោះ ឆោម ភង (ជាចុងបណ្តឹងសាទុក្ខ) ផ្ទេរសិទ្ធិឱ្យឈ្មោះកែវ ឃិន ភេទស្រី អាយុ៤៤ឆ្នាំ មុខរបរនៅផ្ទះ ទីលំនៅភូមិសុវណ្ណសាគរ ឃុំកំពង់កណ្តាល ស្រុកកំពង់បាយ ខេត្តកំពត ។

មានលោក ហាក់ សៀកលី ជាមេធាវី និងជាតំណាង ។

ចុងចម្លើយឈ្មោះ ចាន់ ប៊ុនឡើង (ជាម្ចាស់បណ្តឹងសាទុក្ខ) ភេទប្រុស អាយុ៣១ឆ្នាំ ជាតិខ្មែរ មុខរបរ មន្ត្រីសេដ្ឋកិច្ចសាលាខេត្តតាកែវ ទីលំនៅភូមិស្ពោរ ឃុំរកាក្នុង ស្រុកដូនកែវ ខេត្តតាកែវ ។

**កម្មវត្ថុបណ្តឹង** : ប្តឹងទាមទារដី១៨ម x ៣០ម និងផ្ទះ ៤ម x ៨ម ។

បានឃើញបណ្តឹងសាទុក្ខលេខ ៣១៨ ចុះថ្ងៃទី២០ ខែសីហា ឆ្នាំ២០០៣ របស់ឈ្មោះ ម៉ាន់ ប៊ុនធឿន ប្តឹងមិនសុខចិត្តនឹងសាលដីការដ្ឋប្បវេណីលេខ ៥៩"ច" ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០០៣ របស់សាលាឧទ្ធរណ៍ត្រង់ចំណុចសេចក្តីសំរេចទាំងមូល ។

បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ ៨១ ចុះថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០០៤ របស់តុលាការកំពូល ។

តាមពាក្យបណ្តឹងចុះថ្ងៃទី១០-៦-២០០១ របស់ដើមចោទឈ្មោះឆោម ភង ថាខ្លួនប្តឹងទាមទារដីទំហំ១៨ម x ៣០ម រួមទាំងផ្ទះទំហំ ៤ម x ៨ម ដោយអាងហេតុថា ក្រោយពេលកូនស្រីខ្លួនឈ្មោះកែវ ថាយ រៀបអាពាហ៍ពិពាហ៍រួចហើយ ពុំមានកន្លែងស្នាក់នៅ ខ្លួនក៏ឱ្យកូនរស់នៅលើផ្ទះ និងដីនេះ រួមជាមួយខ្លួនដែរ ។ កូនឈ្មោះកែវ ថាយ និងប្តីឈ្មោះម៉ាន់ ប៊ុនធឿន រួមរស់ជាមួយគ្នា បង្កើតបានកូន០២នាក់ ។ ក្រោយមកកូនប្រសារឈ្មោះម៉ាន់ ប៊ុនធឿន ចេះតែរករឿងបង្កទំនាស់ជាមួយប្រពន្ធ និងខ្លួនជាញឹកញាប់ បានចុះចោលផ្ទះទៅមានស្រីផ្សេងទៀត ពុំគិតគូរប្រពន្ធកូនឡើយ រហូតដល់កូនស្រីខ្លួនធ្លាក់ខ្លួនឈឺ ក៏ឈ្មោះម៉ាន់ ប៊ុនធឿន ពុំបានគិតគូរថែទាំប្រពន្ធដែរ។

លុះដល់ថ្ងៃទី០៨-៦-២០០១ ដោយសភាពជំងឺមានលក្ខណៈធ្ងន់ធ្ងរពុំអាចព្យាបាលបាន កូនស្រីខ្លួនក៏បានទទួលមរណភាព ហើយបន្សល់ទុកកូនកំព្រាទាំងពីរនាក់ ។ ក្នុងរឿងនេះ ខ្លួនប្តឹងទាមទារដី និងផ្ទះនេះវិញ ព្រោះខ្លាចថ្ងៃក្រោយ ឈ្មោះម៉ាន់ ប៊ុនធឿន យកស្រីផ្សេងមករស់នៅលើផ្ទះ និងដីនេះ ហើយទាមទារទុកជាកម្មសិទ្ធិរបស់ពួកគេ ។

បានឃើញសាលក្រមរដ្ឋប្បវេណីលេខ ២៥"ខ" ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០០២ របស់តុលាការខេត្តតាកែវ ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ :

១-ទទួលពាក្យបណ្តឹង ចុះថ្ងៃទី១០-០៦-២០០១ របស់ដើមចោទឈ្មោះឆោមភង ទុកជាត្រឹមត្រូវតាមទំរង់ និងគតិច្បាប់ ។

២-ទទួលស្គាល់លិខិតផ្ទេរសិទ្ធិចុះថ្ងៃទី០៨-១០-២០០១ របស់ដើមចោទឈ្មោះឆោម ភង ដែលបានផ្ទេរទៅឱ្យតំណាងឈ្មោះកែវ យិន ទុកជាត្រឹមត្រូវតាមទំរង់ និងគតិច្បាប់ ។

៣-ដីទំហំ ៦០៣ម$^២$ មានព្រំប្រទល់ខាងជើងទល់ឈ្មោះតាន់ ឆេងហ៊ួយ ខាងត្បូងទល់ផ្លូវ ខាងកើតទល់ឈ្មោះឆក ខាងលិចទល់ឈ្មោះកុយ ជិន ស្ថិតនៅភូមិស្មោរ ឃុំរកាក្នុង ស្រុកដូនកែវ ខេត្តតាកែវ និងផ្ទះដែលសង់លើដីទំនាស់ ត្រូវប្រគល់ឱ្យទៅដើមចោទឈ្មោះឆោមភង តំណាងដោយឈ្មោះកែវ យិន ជាកម្មសិទ្ធិករតាមច្បាប់ តាមបញ្ញត្តិមាត្រាទី១៣៨ និង ១៣៩ នៃច្បាប់ភូមិបាល ។

៤-បង្គាប់ឱ្យឈ្មោះឆោម.ភង "ដើមចោទ" តំណាងដោយឈ្មោះកែវ យិន ចេញប្រាក់ចំនួន ១.០០០.០០០៛ (មួយលានរៀល) ឱ្យទៅឈ្មោះម៉ាន់ ប៊ុនធឿន "ចុងចំលើយ" ជាប្រាក់ដែលចុងចំលើយបានរួមចំណែកក្នុងការសាងសង់ផ្ទះ ។

៥-បង្គាប់ឱ្យចុងចំលើយឈ្មោះម៉ាន់ ប៊ុនធឿន បង់ប្រាក់ប្រដាប់ក្តី គឺពន្ធចុះបញ្ជីក្តី និងពន្ធហ្វ៊ីង១៨០០៛ រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ចំនួន២០០៛ និងចំណាយលើអ្នកប្រគល់ដីកាកោះ ចំនួន ៥០០០៛ សរុប ៧០០០៛ ។ ប្រាក់នេះបានកាត់យកពីប្រាក់ចំនួន ៧០០០៛ ដែលដើមចោទ បានបង់ទុករួច ។

កាលបើផុតកំណត់ឧទ្ធរណ៍ :

= បង្គាប់ឱ្យចុងចំលើយសងប្រាក់ចំនួន ៧០០០៛ ទៅដើមចោទវិញ ។

- បង្គាប់ឱ្យចុងចំលើយបង់ប្រាក់ពន្ធសមាមាត្រចំនួន១%លើតំលៃដី និងផ្ទះទំនាស់ ប្រាក់នេះត្រូវបង់ចូលថវិការដ្ឋចំនួន ៨០% និងរង្វាន់ក្រឡាបញ្ជីទូទាំងប្រទេសចំនួន ២០% ។

សាលក្រមនេះ ជំនុំជំរះ និងប្រកាសជាសាធារណៈចំពោះមុខគូក្តីទុកសិទ្ធិឱ្យប្តឹង ឧទ្ធរណ៍កំណត់២ខែ គិតចាប់តាំងពីថ្ងៃប្រកាសសាលក្រម ។

បានឃើញបណ្តឹងឧទ្ធរណ៍លេខ ៧៩ ចុះថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០០២ របស់ឈ្មោះ កែវ យិន ប្តឹងមិនសុខចិត្តនឹងសាលក្រមរដ្ឋប្បវេណីលេខ ២៥"ខ" ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០០២ របស់តុលាការខេត្តតាកែវ ត្រង់ចំណុចទី៤ នៃសេចក្តីសំរេចនៃសាលក្រម ។

បានឃើញបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី១៥ ខែសីហា ឆ្នាំ២០០២ របស់ឈ្មោះម៉ាន់ ប៊ុនធឿន ប្តឹងមិនសុខចិត្តនឹងសាលក្រមរដ្ឋប្បវេណីលេខ ២៥"ខ" ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០០២ របស់តុលាការខេត្តតាកែវ ត្រង់ចំណុចនៃសេចក្តីសំរេចនៃសាលក្រមទាំងមូល ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ ៥៩"ច" ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០០៣ របស់ សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ :

១-ទទួលពាក្យបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី១៥-៨-២០០២របស់ឈ្មោះម៉ាន់ ប៊ុនធឿន ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ តែបដិសេធចោលដោយខ្វះមូលដ្ឋានគតិច្បាប់ ។

២-ទទួលពាក្យបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី០៩-៩-២០០២ របស់ឈ្មោះកែវ យិន ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ តែបដិសេធចោលដោយខ្វះមូលដ្ឋានគតិច្បាប់ ។

៣-តំកល់សាលក្រមរដ្ឋប្បវេណីលេខ ២៥"ខ" ចុះថ្ងៃទី១៦-៧-២០០២ របស់ តុលាការខេត្តតាកែវ ទុកជាបានការដដែល ។

៤-កាត់យកប្រាក់ប្រដាប់ក្តីជាន់សាលាឧទ្ធរណ៍ចំនួន១៣.០០០៛ គឺពន្ធចុះបញ្ជីក្តី

និងពន្ធហ្គ្រឹងចំនួន ២៩៥០៛ រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ចំនួន ៤៥០៛ ចំណាយលើកិច្ចប្រគល់ដីកាកោះចំនួន៥០០០៛ និងលើអាជ្ញាធរតុលាការចំនួន៥០០០៛ ។

៥-សាលដីកានេះជំនុំជំរះនិងប្រកាសជាសាធារណៈចំពោះមុខគូក្តី បើកផ្លូវប្តឹងសាទុក្ខតាមកំណត់ច្បាប់ ។

បានឃើញបណ្តឹងសាទុក្ខលេខ ៣១៨ ចុះថ្ងៃទី២០ ខែសីហា ឆ្នាំ២០០៣ របស់ឈ្មោះម៉ាន់ ប៊ុនធឿន ប្តឹងមិនសុខចិត្តនឹងសាលដីការដ្ឋប្បវេណីលេខ ៥៩"ច" ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០០៣ របស់សាលាឧទ្ធរណ៍ត្រង់ចំណុចសេចក្តីសំរេចទាំងមូល ។

បានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការថា : សាលដីការដ្ឋប្បវេណីលេខ ៥៩"ច"ចុះថ្ងៃទី២៧-៦-២០០៣ របស់សាលាឧទ្ធរណ៍ ដែលបានសំរេចសេចក្តីមកនេះមានលក្ខណៈត្រឹមត្រូវតាមទំរង់ និងគតិច្បាប់ហើយ ។

អាស្រ័យហេតុនេះ សូមក្រុមប្រឹក្សាជំនុំជំរះ មេត្តាពិនិត្យ និងសំរេច ។

បានស្តាប់សេចក្តីសន្និដ្ឋានរបស់លោកហាក់ សៀកលី ជាមេធាវីតំណាង និងការពារឱ្យដើមចោទបានលើកឡើងថា :ដីទំនាស់ទំហំ ៦០៣ម$^2$ ជាទ្រព្យដើមរបស់ដើមចោទ ។ ឈោម ភង បានអនុញ្ញាតឱ្យប្តីប្រពន្ធរស់នៅលើដីនេះ ហើយគាត់ក៏បានរស់នៅលើដីនេះដែរ ។ សាក្សីដែលជាម្ចាស់ដីបានឆ្លើយហើយថា ដីនេះជាដីឈោម ភង ទិញពីគាត់ ។

សំណូមពរ : សុំតំកល់សាលដីការបស់សាលាឧទ្ធរណ៍ទុកជាបានការដដែល ។

- ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីដើមចោទ
- ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## តុលាការកំពូល

- យល់ឃើញថា បណ្តឹងសាទុក្ខលេខ ៣១៨ ចុះថ្ងៃទី២០ ខែសីហា ឆ្នាំ២០០៣ របស់ឈ្មោះម៉ាន់ ប៊ុនធឿន ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះ មកជំនុំជំរះបានតាមមាត្រា១៨នៃច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្តី ។

- យល់ឃើញថា មានភស្តុតាងគ្រប់គ្រាន់បញ្ជាក់ថា ដី និងផ្ទះទំនាស់ គឺជាទ្រព្យសម្បត្តិរបស់ដើមចោទ បានទិញ និងសង់ផ្ទះដោយផ្ទាល់ ហើយបានប្រគល់ឱ្យកូនស្រីឈ្មោះ កែវ ថាយ

និងប្តីស្នាក់អាស្រ័យនៅក្រោយពេលកូនរៀបអាពាហ៍ពិពាហ៍ ដូចមានចំលើយសាក្សីឈ្មោះគឹម ផែន ស៊ីម ជា ដែលបានឆ្លើយប្រហាក់ប្រហែលគ្នាថា ដីទំនាស់ជាដីដែលដើមចោទត្រូវជាម្តាយនាងកែវ ថាយ បានទិញពីឈ្មោះស៊ីម ជា តាំងពីមុននាងកែវ ថាយ រៀបអាពាហ៍ពិពាហ៍មកម្ល៉េះ រីឯផ្ទះលើដីក៏ឈ្មោះឆោម កង ជាអ្នកចេញប្រាក់ធ្វើដែរ នាងកែវ ថាយ និងប្តីមានសិទ្ធិត្រឹមតែស្នាក់អាស្រ័យនៅប៉ុណ្ណោះ ។

- យល់ឃើញថា ការបំភ្លឺរបស់ប្រធានការិយាល័យដែនដីនគរូបនីយកម្មសំណង់ និងភូមិបាលស្រុក តាមលិខិតលេខ ១៣១/០២ ចុះថ្ងៃទី១៩-៦-២០០២ បញ្ជាក់ថា : នៅក្នុងអំឡុងឆ្នាំ ២០០២ ឈ្មោះម៉ាន់ ប៊ុនធឿន បានសុំខ្ចីពាក្យសុំកាន់កាប់ដីពីការិយាល័យភូមិបាលស្រុក ទៅថតចំលងទុកមើល ពេលយកមកវិញ មានថែមឈ្មោះម៉ាន់ ប៊ុនធឿន និងស្នាមមេដៃទៀតផង ។

- យល់ឃើញថា ដី និងផ្ទះទំនាស់ជាទ្រព្យសម្បត្តិដើមរបស់ឈ្មោះកែវ ថាយ ឈ្មោះម៉ាន់ ប៊ុនធឿន គ្រាន់តែមានសិទ្ធិស្នាក់អាស្រ័យនៅលើផ្ទះនេះតែប៉ុណ្ណោះ សិទ្ធិស្នាក់អាស្រ័យនៅនេះ ត្រូវអស់សុពលភាពដោយចំណងអាពាហ៍ពិពាហ៍ត្រូវរលត់តាមមរណភាពនៃឈ្មោះកែវ ថាយ។ ដូច្នេះផ្ទះ និងដីនេះ ត្រូវធ្លាក់មកលើទាយាទកូនទាំងពីរ ។

- យល់ឃើញថា លោកម៉ាន់ ប៊ុនធឿន បានទទួលលិខិតបង្គាប់ឱ្យធ្វើសារណាការពាររឿងក្តីរបស់ខ្លួនជូនមកតុលាការកំពូលរួចហើយ ប៉ុន្តែពុំបានធ្វើសារណាតាមការកំណត់ទេ ហើយក៏ពុំបានមកចូលរួមសវនាការនេះទេ ដូច្នេះតុលាការកំពូលជំនុំជំរះរឿងនេះ កំបាំងមុខ ប៉ុន្តែចាត់ទុកជាចំពោះមុខ ។

- យល់ឃើញថា ដើមចោទពុំបានមកចូលរួមសវនាការនេះទេ ប៉ុន្តែលោកមេធាវីរបស់ដើមចោទ បានមកចូលរួមហើយ ដូច្នេះតុលាការកំពូលជំនុំជំរះកំបាំងមុខ ប៉ុន្តែចាត់ទុកជាចំពោះមុខ

- យល់ឃើញថា សាលដីការដ្ឋប្បវេណីលេខ ៥៩"ច"ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០០៣ របស់សាលាឧទ្ធរណ៍ដែលបានសំរេចសេចក្តីមកនេះមានលក្ខណៈត្រឹមត្រូវតាមទំរង់និងគតិច្បាប់ហើយ

**ហេតុដូច្នេះ**

**វិនិច្ឆ័យសេចក្តីកំបាំងមុខដួភាគី ប៉ុន្តែចាត់ទុកជាចំពោះមុខ**

១-ទទួលបណ្តឹងសាទុក្ខលេខ ៣១៨ ចុះថ្ងៃទី២០ ខែសីហា ឆ្នាំ២០០៣ របស់ឈ្មោះម៉ាន់ ប៊ុនធឿន ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយខុសនឹងគតិច្បាប់ ។

២-តំកល់សាលដីការដ្ឋប្បវេណីលេខ ៥៩"ច" ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០០៣ របស់សាលាឧទ្ធរណ៍ទុកជាបានការពេញទាំងមូល ។

៣-រឹបអូសប្រាក់ប្រដាប់ក្តីចំនួន១៩០០០៛ ដែលដើមចោទ បានបង់គឺ :

-ពន្ធចុះបញ្ជីក្តី នឹងពន្ធហ្វ៊ីងចំនួន៤.០០០៛ ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន ៨០០៛ សំរាប់ជារង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់.

-ចំណាយលើការប្រគល់ដីកាកោះចំនួន១៥.០០០៛ សរុប១៩.០០០៛ ។

បង្គាប់ឱ្យចុងចំលើយ បង់ពន្ធសមាមាត្រតាមការកំណត់របស់តុលាការខេត្តតាកែវ ។

៤-សាលដីកានេះ ប្រកាសនាសវនាការជាសាធារណៈនៅថ្ងៃទី០៣ ខែមករា ឆ្នាំ២០០៦។